# សុន្ទរកថា
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពីការពិគ្រោះយោបល់លើសេចក្តីព្រាង
# ឯកសារទស្សនទានសម្រាប់ការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាម
# បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០)
# ក្រសួងមហាផ្ទៃ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស សមាជិក សមាជិកានៃអង្គសិក្ខាសាលាជាតិជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយដែលបានមកចូលរួមក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពីការពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទានដ៏មានសារៈសំខាន់ និងជាមូលដ្ឋានដើម្បីរៀបចំកម្មវិធីជាតិដំណាក់កាលទី២នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ គ.ជ.អ.ប. ដែលមាន**សម្តេចក្រឡាហោម** ជាប្រធានដឹកនាំសម្របសម្រួលកិច្ចដំណើរការទូទៅពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្រេចបាននូវសមិទ្ធផលជាច្រើនគួរជាទីមោទនៈក្នុងរយៈពេលកន្លងមកនេះ។

ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាក្នុងការគាំទ្រ និងអនុវត្តការកែទម្រង់ដ៏មានសារៈប្រយោជន៍នេះ សម្រាប់ការពង្រឹងអភិបាលកិច្ចល្អក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសង្កេតឃើញថា ការអនុវត្តគោលនយោបាយកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេស ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំកន្លងមក សម្រេចបាននូវលទ្ធផលជាផ្លែផ្កាជាច្រើន ជាពិសេសពាក់ព័ន្ធទៅនឹងការកែសម្រួល និងការពង្រឹងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែល

បានរៀបចំដាក់ឱ្យដំណើរការផ្អែកតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។ សិទ្ធិអំណាចក្នុងការគ្រប់គ្រង ការចាត់ចែងមុខងារ និងធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈចាំបាច់នានាត្រូវបាននឹងកំពុងផ្ទេរពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ម្យ៉ាងទៀត យន្តការទាំងឡាយដែលបានបង្កើតឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងដំណើរការប្រកបដោយតម្លាភាពក្នុងការអភិវឌ្ឍមូលដ្ឋាន និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ជាពិសេស ការទប់ស្កាត់ការឆ្លង និងរីករាលដាលជំងឺកូវីដ-១៩ និងការជួយសង្គ្រោះប្រជាពលរដ្ឋបានទាន់ពេលវេលាពីជំនន់ទឹកភ្លៀងនាពេលកន្លងមកថ្មីៗនេះ។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី**

ការកំណត់ចក្ខុវិស័យនានាសម្រាប់រយៈពេល១០ឆ្នាំបន្ទាប់ទៀត ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ពាក់ព័ន្ធទៅនឹងការជំរុញកិច្ចដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅ និងប្រកបដោយប្រសិទ្ធភាព ពិតជាមានសារៈសំខាន់សម្រាប់កម្ពុជា។ ទន្ទឹមនេះ ផ្អែកលើខ្លឹមសារនៃសេចក្តីព្រាងឯកសារទស្សនទាន និងរបាយការណ៍បូកសរុបលទ្ធផលសិក្ខាសាលានេះ ខ្ញុំសូមផ្តល់នូវគោលការណ៍ណែនាំសម្រាប់ការកែទម្រង់វិមជ្ឈការ ដែលយើងត្រូវខិតខំប្រឹងប្រែងរួមគ្នាសម្រេចឱ្យបានក្នុងរយៈពេល១០ឆ្នាំបន្តទៀតដូចខាងក្រោម៖

**ទីមួយ៖ អំពីការពង្រឹងការគ្រប់គ្រងកិច្ចដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

រាជរដ្ឋាភិបាលនឹងបន្តជំរុញការកែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗដទៃទៀត។ ក្នុងស្មារតីនេះ តួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានលើកកម្ពស់ តាមរយៈការបន្តផ្ទេរសិទ្ធិអំណាច មុខងារធនធាន និងការទទួលខុសត្រូវចាំបាច់នានាជាបន្តបន្ទាប់ពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

គ.ជ.អ.ប.ត្រូវខិតខំបន្តពង្រឹងការដឹកនាំ និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ននៃវិស័យសាធារណៈពាក់ព័ន្ធនានា ហើយក្រសួង ស្ថាប័ននីមួយៗត្រូវបន្តផ្ទេរសិទ្ធិអំណាច មុខងារធនធាន និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែងការផ្តល់សេវាសាធារណៈចាំបាច់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្នសង្គម។

**ទីពីរ៖ អំពីការពង្រឹងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន**

ក្នុងន័យនេះ ដើម្បីរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានរយៈពេល១០ឆ្នាំបន្តទៀត ខ្ញុំសូមផ្តល់នូវគោលការណ៍ណែនាំ៣ចំណុចដូចខាងក្រោម ៖

**១. ការសិក្សា និងការរៀបចំរាជធានីភ្នំពេញឱ្យក្លាយជាក្រុងមេត្រូប៉ូលីទែន**

បច្ចុប្បន្នទីក្រុងភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏ជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈពិសេសប្រៀបធៀបនឹងខេត្ត ឬក្រុងដទៃទៀតរបស់កម្ពុជា។ រាជធានីភ្នំពេញជាមជ្ឈមណ្ឌលអាជីវកម្ម ផលិតកម្ម ពាណិជ្ជកម្ម សេវាកម្ម និងសម្រាប់បំពេញការងាររដ្ឋបាលនានាទាំងកម្រិតជាតិ និងអន្តរជាតិយ៉ាងទូលំទូលាយ។ តំបន់ជាយក្រុងភ្នំពេញបាន និងកំពុងអភិវឌ្ឍយ៉ាងលឿនទៅជាទីក្រុងរណបនៃរាជធានីភ្នំពេញដែលមានប្រជាជនរស់នៅយ៉ាងច្រើនកុះករ ជាមួយនឹងបញ្ហាប្រឈមជាច្រើន រួមមាន បរិស្ថាន ចរាចរណ៍ និងអនាម័យដែលចាំបាច់ត្រូវរៀបចំតាមប្រព័ន្ធគ្រប់គ្រងទីក្រុងធំៗ ឬហៅជាសកលថា << **មាតុមហាធានី** >> **(មេត្រូប៉ូលីទែន** Metropolitan ) **មាតុ ប្រែថាកំណើត មហា ប្រែថាអស្ចារ្យ សម្បើម កុះករ សំបូរបែប និងធានី ប្រែថា ទីកន្លែង ក្រុងជាដើម ដូច្នេះ <<មាតុមហាធានី>> សំដៅដល់ទីក្រុងដែលមានមនុស្សម្នារស់នៅច្រើន** ដើម្បីធានាដល់ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈប្រកប ដោយប្រសិទ្ធភាពជាមួយនឹងការកំណត់ឡើងវិញនូវសិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់ លាស់រវាងរដ្ឋបាលរាជធានីភ្នំពេញជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ និងក្រសួង ស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធដែលមានទីតាំងនៅរាជធានីភ្នំពេញផងដែរ។

**២. ការរៀបចំរដ្ឋបាលក្រុង ស្រុកនានាទៅជារដ្ឋបាលមូលដ្ឋានជួរមុខ**

រដ្ឋបាលក្រុង ស្រុកត្រូវពង្រឹងខ្លួនឱ្យក្លាយជារដ្ឋបាលមូលដ្ឋានដែលមានតួនាទី និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋតាមរយៈការប្រាស្រ័យទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ទន្ទឹមនេះ ចំពោះក្រុង ឬស្រុកដែលមានលក្ខណៈជាទីប្រជុំជន ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងផ្តោតសំខាន់ទៅលើការផ្តល់សេវាទីប្រជុំជនឱ្យមានលក្ខណៈល្អប្រសើរលើគ្រប់ផ្នែក។ ដោយឡែកចំពោះស្រុកដែលមានលក្ខណៈជាតំបន់ជនបទ ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងផ្តោតសំខាន់លើវិស័យកសិកម្ម និងការអភិវឌ្ឍជនបទឱ្យបានល្អប្រសើរ។

**៣. ការសិក្សា និងរៀបចំរដ្ឋបាលខេត្តឱ្យមានចរិតលក្ខណៈជារដ្ឋបាលតំបន់**

ក្នុងន័យនេះ រដ្ឋបាលខេត្តត្រូវបំពេញមុខងារសំខាន់ ៣ គឺ៖ **១.** មុខងារតំណាងឱ្យថ្នាក់ជាតិ ហើយត្រូវអនុវត្តនូវមុខងារនានាដែលរាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្ម **២.** គាំទ្រ តាមដាន

ត្រួតពិនិត្យការបំពេញការងាររដ្ឋបាលមូលដ្ឋាន ការគ្រប់គ្រងទិន្នន័យព័ត៌មាន និងការរៀបចំផែនការអភិវឌ្ឍដែលមានលក្ខណៈជាយុទ្ធសាស្ត្ររបស់ខេត្តនីមួយៗ និង៣. ត្រូវអនុវត្តមុខងារក្នុងការគ្រប់គ្រងសេវាសាធារណៈ និងគម្រោងអភិវឌ្ឍធំៗមួយចំនួនដែលមានលក្ខណៈបច្ចេកទេសខ្ពស់ហើយដែលក្រុង ស្រុកមិនអាចអនុវត្តបាន។

**ទីបី៖អំពីការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ដើម្បីពព្រឹងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានប្រកបដោយគុណភាព រដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមាន រដ្ឋបាលក្រុង ស្រុក ចាំបាច់ត្រូវមានតួនាទី និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះ មន្ត្រីជំនាញបច្ចេកទេសភាគច្រើននឹងត្រូវផ្ទេរពីក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ ដើម្បីដាក់ពង្រាយឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ត្រូវធ្វើការកែលំអឡើងវិញនូវចំណុចខ្វះខាតទាំងឡាយ សំដៅធានាដល់ការលើកទឹកចិត្តមន្ត្រីសាធារណៈ ឱ្យស្ម័គ្រចិត្តទៅបំពេញការងារនៅរដ្ឋបាលមូលដ្ឋានតាមរយៈការផ្តល់ថវិកាបន្ថែមលើប្រាក់បៀវត្ស និងការឧបត្ថម្ភផ្សេងៗ ព្រមទាំងការដំឡើងកម្រិតថ្នាក់ និងឋានន្តរស័ក្តិក្នុងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងទំហំការងារ និងបង្កលក្ខណៈឱ្យមានភាពងាយស្រួលក្នុងការផ្ទេរមន្ត្រីដែលមានសមត្ថភាពតាមវិស័យជំនាញពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ។ ត្រូវផ្តល់ឱកាសដល់មន្ត្រីក្នុងការអភិវឌ្ឍសមត្ថភាពរៀងៗខ្លួនតាមមុខជំនាញនៅក្នុងវគ្គបណ្តុះបណ្តាលដែលជាកាតព្វកិច្ចក្នុងការអភិវឌ្ឍធនធានមនុស្ស។

**ទីបួន៖ អំពីការផ្ទេរធនធានហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

រាជរដ្ឋាភិបាលនឹងគិតគូរពិចារណាអំពីការប្រគល់នូវមូលដ្ឋានពន្ធ និងមិនមែនសារពើពន្ធបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព និងការប្រកួតប្រជែងក្នុងការប្រមូលចំណូលទាំងក្នុងក្របខ័ណ្ឌជាចំណូលពីមូលដ្ឋានរបស់ខ្លួន និងសំដៅកាត់បន្ថយនូវការពឹងផ្អែកទាំងស្រុងតែទៅលើការបែងចែកថវិកាពីថ្នាក់ជាតិ។

ចំពោះ "**កញ្ចប់ថវិកាពិសេស**" ក៏នឹងត្រូវរៀបចំបង្កើតឡើងក្នុងគោលបំណងជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈទន់ខ្សោយដើម្បីជំរុញល្បឿននៃការអភិវឌ្ឍនៅតាមតំបន់ និងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់នានានៅទូទាំងប្រទេស ជាពិសេសជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបន្ថែមដល់តំបន់ដែលជាប៉ូលសេដ្ឋកិច្ចសំខាន់ៗរបស់ជាតិ និងការពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងសវនកម្មហិរញ្ញវត្ថុ ដើម្បីធានាបាននូវការគ្រប់គ្រង ការចាត់ចែងប្រើប្រាស់ ហើយយន្តការត្រួតពិនិត្យទាំងនោះត្រូវរៀបចំឱ្យមានលក្ខណៈជាប្រព័ន្ធ ផ្អែកលើគោលការណ៍ និងផែនការកម្មវិធីច្បាស់លាស់ដើម្បីធានាការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព គណនេយ្យភាព។

**ទីប្រាំ៖ អំពីការរៀបចំ និងពង្រឹងប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការរៀបចំបង្កើតរដ្ឋបាលអេឡិត្រូនិច ឬការបង្កើតប្រព័ន្ធអភិបាលកិច្ចអេឡិត្រូនិចនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការកែទម្រង់វិមជ្ឍការ និងវិសហមជ្ឍការពិតជាមានសារៈប្រយោជន៍សម្រាប់ការប្រើប្រាស់នូវបច្ចេកវិទ្យាពត៌មានក្នុងការអនុវត្តនីតិវិធីបំពេញការងារ ការប្រាស្រ័យទាក់ទងជាមួយស្ថាប័ននានា និងការផ្តល់សេវាសាធារណៈ និងពត៌មានជូនប្រជាពលរដ្ឋ។ គុណតម្លៃនៃរដ្ឋបាលអេឡិចត្រូនិច គឺចំណាយប្រតិបត្តិការតិច កាត់បន្ថយការិយាធិបតេយ្យ ផ្តល់ពត៌មានកាន់តែទូលំទូលាយ និងឆាប់រហ័ស ដើម្បីលើកកម្ពស់ការចូលរួមផ្តល់យោបល់ពីប្រជាពលរដ្ឋ និងការធានាដល់ការផ្តល់សេវាសាធារណៈបានយ៉ាងឆាប់រហ័ស និងទាន់ពេលវេលា។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអង្គសិក្ខាសាលាជាពិសេសការបន្តចូលរួមរបស់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងការរៀបចំឯកសារលម្អិតនៃកម្មវិធីជាតិដំណាក់កាលទី២សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅធានាជំរុញការអនុវត្តការកែទម្រង់ដ៏មានសារៈសំខាន់នេះ សម្រេចបានជោគជ័យតាមចក្ខុវិស័យ និងសមិទ្ធផលដែលបានរំពឹងទុក ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍជាតិការលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាពលរដ្ឋកាន់តែល្អប្រសើរឡើង។

ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តបង្កើនល្បឿន ពង្រឹងការអនុវត្តកម្មវិធីកែទម្រង់វិមជ្ឍការនិងវិសហមជ្ឍការឱ្យកាន់តែស៊ីជម្រៅ និងមានតម្លាភាព ដើម្បីប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា។

ជាទីបញ្ចប់ ជាមួយនឹងការប្រកាសបិទសិក្ខាសាលាជាតិស្តីពីការពិគ្រោះយោបល់លើឯកសារទស្សនទានសម្រាប់ការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ( ២០២១-២០៣០ ) នាពេលនេះ ខ្ញុំសូមប្រសិទ្ធពរជូន**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសិក្ខាសាលា** សូមប្រកបដោយពុទ្ធពរ និងពរទាំង៥ប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**